**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សាររលិខិតរំលែកមរណទុក្ខ

**ផ្ញើជូន**

**លោកជំទាវ ខៀវ វណ្ណា ព្រមទាំងក្រុមគ្រួសារ**

លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន !

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា ឯកឧត្តមសាស្ត្រាចារ្យ **ហេង តៃគ្រី** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល ដែលត្រូវជាស្វាមីរបស់លោកជំទាវ បានទទួលមរណភាពនៅថ្ងៃអាទិត្យ ១០កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង១២:១០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ៧៧ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ឯកឧត្តមសាស្ត្រាចារ្យ **ហេង តៃគ្រី** មិនត្រឹមតែជាការបាត់បង់នូវស្វាមី ដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា និងជាការបាត់បង់ឪពុក ឪពុកក្មេក និងជីតា ដែលប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗ និងចៅៗប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់នូវឥស្សរជនជាន់ខ្ពស់មួយរូបដែលតែងបានលះបង់កម្លាំងកាយ ចិត្ត បញ្ញា ស្មារតីក្នុងបុព្វហេតុជាតិមាតុភូមិ ជាពិសេសបានរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងវិស័យសុខាភិបាល និងបានចូលរួមចំណែកលើកកម្ពស់សុខភាពសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពជូនប្រជាជនកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់ឯកឧត្តមសាស្ត្រាចារ្យ **ហេង តៃគ្រី** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវ ខៀវ វណ្ណា ព្រមទាំងក្រុមគ្រួសារ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**